៣- ឃុំរលួសមានប្រាំមួយភូមិដែលកាត់យកពីឃុំស្វាយចេកគឺ ៖ ភូមិស្ពឹង ភូមិខ្វាវកើត ភូមិស្លែង ភូមិបែកចានថ្មីភូមិតាអុងកើត ភូមិរលួស ។

**មាត្រា ២ ៖** ត្រូវបានបំបែកភូមិសាស្ត្រស្រុកថ្មពួក ជាពីរស្រុកគឺ ៖ ស្រុកស្វាយចេក និងស្រុកថ្មពួក ។

-ស្រុកស្វាយចេកមានឃុំចំណុះចំនួនប្រាំបី គឺ ឃុំស្វាយចេក ឃុំរលួស ឃុំតាបែន ឃុំស្លក្រាម ឃុំសារង្គ ឃុំតាផូ ឃុំផ្គាំ ឃុំទ្រាស ។ ទីតាំងរដ្ឋបាលរបស់សាលាស្រុកស្វាយចេក តាំងនៅភូមិស្ពឹង ឃុំស្វាយចេក ។

-ស្រុកថ្មពួកមានឃុំចំណុះចំនួនប្រាំមួយគឺ ៖ ឃុំថ្មពួក ឃុំគោកកបិន ឃុំគំរូ ឃុំបន្ទាយឆ្មារ ឃុំភូមិថ្មី ឃុំគោករមៀត ។ ទីតាំងរដ្ឋបាលរបស់ស្រុកថ្មពួកតាំងនៅ ភូមិវត្តចាស់ ឃុំថ្មពួក ។

**មាត្រា ៣ ៖** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤ ៖** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន និង អភិបាលខេត្តបន្ទាយមានជ័យ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ច រៀងៗខ្លួន ។

**មាត្រា ៥ ៖** អនុក្រឹត្យនេះមាន អានុភាពគតិយុត្តិចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

***

*រាជធានីភ្នំពេញ ,ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៤*

## អនុក្រឹត្យលេខ ៦៦ អនក្រ
## ស្តីពីការកែសំរួលសមាសភាពគណៈកម្មការជាតិអចិន្ត្រៃយ៍ដើម្បី សំរបសំរួលកិច្ចការឯកជនភាវូបនីយកម្ម និង ការជំរុញវិស័យដំណាំកៅស៊ូ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-យោងអនុក្រឹត្យលេខ ៥២ អនក្រ ចុះថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ១៩៩៤ ស្តីពីការបង្កើតគណៈកម្មការជាតិអចិន្ត្រៃយ៍ដើម្បីសំរបសំរួលកិច្ចការឯកជនភាវូបនីយកម្ម និង ជំរុញវិស័យដំណាំកៅស៊ូ

**សំរេច**

**មាត្រាតែមួយ** : សមាសភាពគណៈកម្មការជាតិអចិន្ត្រៃយ៍ ដើម្បីសំរបសំរួលកិច្ចការឯកជនភាវូបនីយកម្ម និង ការជំរុញវិស័យដំណាំកៅស៊ូ ដែលមានចែងក្នុងមាត្រា ១ នៃអនុក្រឹត្យលេខ ៥២ អនក្រ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ១៩៩៤ ត្រូវបានកែសំរួលដូចតទៅ :

-លោក ហ្វីលិពម៉ូណាំង ទីប្រឹក្សាបច្ចេកទេសអមអគ្គនាយកដ្ឋានកៅស៊ូ ជាសមាជិកសង្កេតការណ៍ ទទួលបន្ទុកជួយឯកឧត្តម **តាច សេខហូរ** និងឯកឧត្តម តេង ឡាវ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

***

*រាជធានីភ្នំពេញ ,ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ១៩៩៤*

# អនុក្រឹត្យលេខ ១២០ អនក្រ
# ស្តីពីការជូន មេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើ ដោយព្រះរាជក្រមចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤·